**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ ០១.២១៧/០៧ គ.ជ.ប.អគ្គ.ពស**

ភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧

# កម្មវិធីផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សនយោបាយ តាមទូរទស្សន៍ជាតិកម្ពុជា ត្រូវអនុវត្តតាមគោលការណ៍សមធម៌

គណបក្សនយោបាយភាគច្រើនក្នុងចំណោមគណបក្សនយោបាយទាំង ១២ បានសម្រេចយករូបមន្តសមធម៌ក្នុងការផ្សព្វផ្សាយគោលនយោបាយរួមរបស់ខ្លួនតាមប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិ គឺ ទូរទស្សន៍ជាតិកម្ពុជា វិទ្យុជាតិកម្ពុជាក៏រិត F M 96 MHz និងវិទ្យុជាតិកម្ពុជា ក៏រិត AM 918 KHz នៅក្នុងអង្គប្រជុំពិសេសមួយដែលរៀបចំឡើងដោយ គ.ជ.ប កាលពីព្រឹកថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ។

ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប បានមានប្រសាសន៍ថា ច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មិនតម្រូវឱ្យមានកម្មវិធីបែបនេះនៅថ្នាក់ជាតិឡើយ ប៉ុន្តែដើម្បីបើកចំហនូវព័ត៌មានអំពីការបោះឆ្នោត ទើប គ.ជ.ប ផ្តល់ឱកាសដល់គណបក្សនយោបាយបានផ្សព្វផ្សាយពីគោលនយោបាយរួមរបស់ខ្លួនតាមប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិទាំង៣ ។

គោលការណ៍សមធម៌ដែលគណបក្សនយោបាយបានសម្រេចយកនោះ គឺថា គណបក្សនយោបាយណាដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ២ ឆ្នាំ ២០០៧ ច្រើនជាង ១០០០ឃុំ សង្កាត់ ទទួលបានម៉ោងផ្សាយ ៦នាទី ១កម្មវិធី ចំណែកគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតិចជាង ១០០០ឃុំ សង្កាត់ ទទួលបានម៉ោងផ្សាយចំនួន ៥នាទី ។

កម្មវិធីផ្សព្វផ្សាយពីគោលនយោបាយរួមរបស់គណបក្សនយោបាយ នឹងគ្រោងចាក់ផ្សាយមួយថ្ងៃ ២ដងនៅអំឡុងពេលនៃការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី២ ឆ្នាំ ២០០៧ ។

សូមបញ្ជាក់ថា គណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនលើសពី ១០០០ឃុំ សង្កាត់ មានចំនួន ៤ គឺ គណបក្សប្រជាជនកម្ពុជា គណបក្សសម រង្ស៊ី គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សនរោត្តម រណឫទ្ធិ ហើយគណបក្សដែលបានចុះបញ្ជីបេក្ខជនក្រោម ១០០០ឃុំ សង្កាត់ មានចំនួន ៨ គឺ គណបក្សប្រជាធិបតេយ្យខ្មែរ គណបក្សរណសិរ្សសង្គមជាតិនិយម គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ គណបក្សហង្សដារ៉ាចលនាប្រជាធិបតេយ្យ គណបក្សប្រជាជាតិខ្មែរ គណបក្សសង្គមប្រជាធិបតេយ្យ គណបក្សសង្គមខ្មែរនិយម និងគណបក្សចំរើននិយមខ្មែរ ។

នៅក្នុងកិច្ចប្រជុំនោះមានគណបក្សនយោបាយចូលរួមចំនួន ១១ ហើយអវត្តមាន ១ គឺ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ។